# ក្រសួងអប់រំ យុវជន និងកីឡា
# Ministry of Education, Youth and Sport

## ថវិកាពលរដ្ឋឆ្នាំ២០២៥
## Citizen Budget Fiscal Year 2025



អាសយដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា
Address: #80, Preah Norodom Blvd. Phnom Penh, Cambodia

## ១. សេចក្តីផ្តើម

សៀវភៅថវិកាពលរដ្ឋ គឺជាឯកសារផ្សព្វផ្សាយព័ត៌មានថវិកាប្រចាំឆ្នាំជូនដល់អ្នកទទួលផលពីសេវាសាធារណៈដែលផ្តល់ដោយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីលើកកម្ពស់ការយល់ដឹងពីការចំណាយថវិការបស់ក្រសួង និងទំនាក់ទំនងរវាងក្រសួង ជាមួយសាធារណជនទូទៅ។

## ២. ចក្ខុវិស័យ

ក្រសួងអប់រំ យុវជន និងកីឡា មានចក្ខុវិស័យកសាង និងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែកដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយទៅជាសង្គមរីកចម្រើន ផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។

## ៣. បេសកកម្ម

ដើម្បីឆ្លើយតបចក្ខុវិស័យនេះ ក្រសួងបានកំណត់បេសកកម្មដឹកនាំគ្រប់គ្រង និងអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជាឱ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌របស់កម្ពុជា និងការរីកចម្រើននៅក្នុងតំបន់ និងសកលលោក។

## ៤. អាទិភាពកំណែទម្រង់វិស័យអប់រំ

១ ការពង្រឹងអភិបាលកិច្ចសាលារៀន

២ ពិនិត្យ និងកែសម្រួលកម្មវិធីសិក្សា និងសកម្មភាពក្រៅម៉ោងសិក្សា

៣ ការលើកកម្ពស់សុខភាពសិក្សា

៤ ការលើកទឹកចិត្តការចូលរួមពីមាតាបិតា អ្នកអាណាព្យាបាល និងសហគមន៍

៥ ការជំរុញការអប់រំឌីជីថល

៦ ការបង្កើតមជ្ឈមណ្ឌលឧត្តមភាពក្នុងគ្រឹះស្ថានឧត្តមសិក្សា

៧ ការកសាងប្រព័ន្ធ និងការអភិវឌ្ឍសមត្ថភាព

៨ អភិវឌ្ឍការអប់រំកាយ និងកីឡា

## ៥. គោលបំណងគោលនយោបាយ និងថវិកាកម្មវិធីឆ្នាំ២០២៥

### គោលបំណងគោលនយោបាយ

ទី១៖ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ការអភិវឌ្ឍយុវជន និងការលើកកម្ពស់វិស័យកីឡា។

ទី២៖ ពង្រឹងសមត្ថភាពស្ថាប័ន ដើម្បីធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់។

### រចនាសម្ព័ន្ធថវិកាកម្មវិធី

| ឈ្មោះកម្មវិធី |
|---|
| កម្មវិធីទី១៖ ការអភិវឌ្ឍការអប់រំក្នុងប្រព័ន្ធក្រៅប្រព័ន្ធ និងមិនផ្លូវការ |
| កម្មវិធីទី២៖ ការអភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវ |
| កម្មវិធីទី៣៖ ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា |
| កម្មវិធីទី៤៖ ការអភិវឌ្ឍយុវជន |
| កម្មវិធីទី៥៖ ការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ |

### គោលបំណងនៃកម្មវិធី

កម្មវិធី ១៖ ពង្រីកសេវាអប់រំកុមារតូចតាមគ្រប់រូបភាពសម្រាប់កុមារអាយុពី០ឆ្នាំទៅក្រោម ៦ឆ្នាំ បង្កើនអត្រាបញ្ចប់ការសិក្សាសម្រាប់ការអប់រំចំណេះទូទៅ និងបង្កើនអត្រាអក្ខរកម្មជនពេញវ័យ។

កម្មវិធី ២៖ ការអភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវឆ្លើយតបនឹងតម្រូវការនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងឧស្សាហកម្ម។

កម្មវិធី ៣៖ លើកកម្ពស់ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា សំដៅលើសុខុមាលភាពប្រជាពលរដ្ឋ និងការប្រកួតកីឡាគ្រប់ប្រភេទឱ្យមានគុណផលកីឡា។

កម្មវិធី ៤៖ អនុវត្តគោលនយោបាយជាតិ និងផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍយុវជនកម្ពុជា និងឆ្លើយតបតាមតម្រូវការចាំបាច់របស់យុវជន។

កម្មវិធី ៥៖ ពង្រឹងអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផល ការងារវិមជ្ឈការ និងវិសហមជ្ឈការ និងការបង្កើតភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន។

## ៦. ថវិកាឆ្នាំ២០២៥




ថវិកាចំណាយចរន្តខាងលើរួមបញ្ចូលថវិការបស់ក្រសួងអប់រំ យុវជន និងកីឡា (រដ្ឋបាលកណ្តាល) មន្ទីរអប់រំ យុវជន នឹងកីឡារាជធានី ខេត្ត និងថវិកាផ្ទេរពាមុខងារទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ចាប់ពីឆ្នាំ២០២៤ ក្រសួងបានផ្ទេរថវិកាទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងក្របខណ្ឌទូទាំងប្រទេស ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រង និងការផ្តល់សេវាអប់រំ យុវជន និងកីឡាប្រកបដោយប្រសិទ្ធភាព គុណភាព គណនេយ្យភាព តម្លាភាព បរិយាបន្ន និងសមធម៌សង្គម។ នៅឆ្នាំ២០២៥ ក្រសួងបានផ្ទេរថវិកាទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលមានឥណទានសរុបចំនួន ១ ៨៤៥ ៥២៥.៩ លានរៀលស្មើនឹង ៤៦% នៃឥណទានចំណាយចរន្តសរុប ក្នុងនោះបន្ទុកបុគ្គលិកចំនួន ១ ៧៣១ ៥៤៧.៦ លានរៀល និងក្រៅបន្ទុកបុគ្គលិកចំនួន ១០៧,៧០៨.៣លានរៀល។






## ៧. ថវិកាសម្រាប់មុខសញ្ញាចំណាយសំខាន់ៗ

### ថវិកាមូលនិធិដំណើរការសាលារៀនសាធារណៈ (លានរៀល)






### អាហារូបករណ៍សិស្សក្រីក្រ

| កម្រិតសិក្សា | ចំនួនសិស្សប៉ាន់ស្មាន (នាក់) | ឥណទាន (លានរៀល) |
|---|---|---|
| បឋមសិក្សា | 354 644 | 85 114,5 |
| មធ្យមសិក្សាបឋមភូមិ | 74 097 | 17 783,3 |
| មធ្យមសិក្សាទុតិយភូមិ | 33 617 | 12 102,2 |
| សុប | **462 358** | **115 000,0** |





## កម្មវិធីស្បៀងអាហារដោយប្រើប្រាស់កសិផលក្នុងសហគមន៍

| បរិយាយ | ចំនួន |
|---|---|
| ចំនួនខេត្ត | 10 ខេត្ត |
| ចំនួនសាលា | 686 សាលា |
| ចំនួនសិស្ស | 191 197 នាក់ |
| ចំនួនឥណទាន | 29 606,3 លានរៀល |



សកម្មភាពសិស្សានុសិស្សទទួលទានអាហារ

## មត្តេយ្យសិក្សាសហគមន៍

| បរិយាយ | ចំនួន |
|---|---|
| ចំនួនថ្នាក់ | 1 438 ថ្នាក់ |
| ចំនួនឥណទាន | 14 402,5 លានរៀល |



សកម្មភាពរៀន និងបង្រៀនរបស់មត្តេយ្យសិក្សាសហគមន៍

# ៨. ស្ថិតិអប់រំឆ្នាំសិក្សា២០២៤-២០២៥

**ចំនួនសាលារៀន**




**ចំនួនថ្នាក់រៀន**




**ចំនួនបន្ទប់រៀន**



## ចំនួនសិស្ស




## ចំនួនបុគ្គលិកអប់រំ

| បរិយាយ | បុគ្គលិកបង្រៀន | | បុគ្គលិកមិនបង្រៀន | | បុគ្គលិកសរុប | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| សាធារណៈ | 95 013 | 51 639 | 21 247 | 6 477 | 116 260 | 58 116 |
| ឯកជន | | | | | 31 776 | 19 882 |
| មត្តេយ្យសិក្សាសហគមន៍ | 3 623 | 3 401 | 21 | 19 | 3,644 | 3 420 |
| សរុប | **98 636** | **55 040** | **21 268** | **6 496** | **151 680** | **81 418** |

ប្រភព៖ សៀវភៅស្ថិតិ និងសូចនាករអប់រំ មត្តេយ្យសិក្សា និងការអប់រំ
ចំណេះទូទៅសម្រាប់សាលារៀនសាធារណៈឆ្នាំសិក្សា២០២៤-២០២៥។

## ៩. លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម័យប្រឡង៖ ០៨ តុលា ២០២៤




ប្រភព៖ សេចក្តីប្រកាសព័ត៌មានលេខ១៤ អយក.សប្រព ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៤
ស្តីពីលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
សម័យប្រឡង៖ ០៨ តុលា ២០២៤







# ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា

## Education Financial Management System (EFMS)

ប្រព័ន្ធ EFMS គឺជាប្រព័ន្ធសម្រាប់ធ្វើស្វ័យប្រវត្តិកម្មនូវដំណើរការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានលក្ខណៈឌីជីថលដោយគ្របដណ្ដប់ទាំងការរៀបចំថវិកា ការអនុវត្តថវិកា ការពិនិត្យស្ថានភាពថវិកា កិច្ចបញ្ជិកា គណនេយ្យសម្ភារៈ និងការធ្វើសវនកម្ម លើគ្រប់ប្រភពថវិកា។

### មុខងារដែលកំពុងដាក់ឱ្យប្រើប្រាស់

- គ្រប់គ្រងថវិការដ្ឋទេយ្យបុរេប្រទាន
- គ្រប់គ្រងថវិកាគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ
- ការវិភាជថវិកា
- បញ្ជាទិញ
- គណនីត្រូវសង
- ចលនាឥណទានថវិកា
- បញ្ជី និងរបាយការណ៍
- គ្រប់គ្រងមូលនិធិដំណើរការសាលារៀនសាធារណៈ
- គ្រប់គ្រងបេសកកម្ម
- កម្មវិធីទូរសព្ទដៃ

### មុខងារកំពុងអភិវឌ្ឍ

- គ្រប់គ្រងថវិកាដៃគូអភិវឌ្ឍន៍
- គ្រប់គ្រងចំណូល
- គ្រប់គ្រងថវិកាដំណើរការការិយាល័យ អប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

# កម្មវិធីទូរសព្ទដៃ
# EFMS Mobile App



Download on the App Store

GET IT ON Google Play

**ទាញយកកម្មវិធីនៅទីនេះ...**

***ហើយចូលប្រើប្រាស់ជាមួយ***
***គណនីប្រព័ន្ធ EFMS របស់លោកអ្នក***


**ទំនាក់ទំនង៖**

efms@moeys.gov.kh

https://efms.moeys.gov.kh

អគារលេខ ៨០ មហាវិថីព្រះនរោត្តម
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា


**ភ្ជាប់ទំនាក់ទំនងតាមបណ្ដាញសង្គម**

# ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន
# ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា




ថ្លែងក្នុងពិធីបិទសន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡា
ឆ្នាំសិក្សា២០២៣-២០២៤ និងលើកទិសដៅឆ្នាំសិក្សា២០២៤-២០២៥
នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៥

*“ ក្រសួងបាននិងកំពុងអនុវត្តថវិកាកម្មវិធីពេញលេញ និងបានធ្វើបច្ចុប្បន្នកម្មរចនាសម្ព័ន្ធកម្មវិធី និងអនុកម្មវិធី ដើម្បីឆ្លើយតបនឹងថវិកាសមិទ្ធកម្ម ការផ្សារភ្ជាប់រវាងគោលនយោបាយ ផែនការ និងថវិកា ក៏ដូចជាការបង្កើនគណនេយ្យភាពរបស់អង្គភាពថវិកា ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា និងការពង្រឹងការគ្រប់គ្រងមូលនិធិដំណើរការសាលារៀន ព្រមទាំងការរៀបចំរបាយការណ៍សមិទ្ធកម្មផងដែរ។ ”*